ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣០)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៩ ២៣២ នាក់ នៃរោងចក្រ សហគ្រាស ទាំង៥៥ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៥៥ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ចន្ទ ៦កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៥៥ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 29 |
| 1 | ក្រុមហ៊ុន ផានថេសសា ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អ៊ីសថិច(ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន មិន រ៉ុង ហ្គាម៉ិន ហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហាយ សេង 168(ខេមបូឌា)ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា) ប្លាស្ទិក អ៊ិនដាស្ទ្រី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន សេនហ្សាន ស៊ូ ខេមបូឌា | ភ្នំពេញ |
| 8 | ក្រុមហ៊ុន សឺង យ៉ុង ហ្គាមែន ហ្វាត់តូរី ខូអេលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ហុងហ្វាស៊ាង អ៊ិនដាសស្រ្ទៀល ឯ.ក | កណ្តាល |
| 10 | ក្រុមហ៊ុន គ័ន ម៉ីង ហ៊ែនប៊ែក (ខេមបូឌា) អ៊ិនដាសស្រ្ទៀល ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុន ខេនផាក (ខេមបូឌា) ឯ.ក | កណ្តាល |
| 12 | ក្រុមហ៊ុន ប៉ូវយើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្តាល |
| 13 | ក្រុមហ៊ុន ស្តារីត (ខេមបូឌា) ឯ.ក | កណ្តាល |
| 14 | ក្រុមហ៊ុន ញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 15 | ក្រុមហ៊ុន លីវ តាន អ៊ីនធើណេសិនណល ខេមបូឌាខូអិលធីឌី | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន សាប្រីណា (ខេមបូឌា) ហ្គាម៉ិន ម៉េនញ៉ូហ្វាក់ធីរីន ខប | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ឆាយណាសូហ៊ែនប៊ែក ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ហុងកុងវីនហ្វៀរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន ហៃនផុន ឡាក់ហ្គេដ (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន ណានវ៉ាង ត្រាវែល ហ្គូដស៍ ឯក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន ប៊ុនតឹសហ្វិតវែរ អិល ធី ឌី | តាកែវ |
| 23 | ក្រុមហ៊ុន ណាញ ស្គាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 24 | ក្រុមហ៊ុន ឡុង ឈឹង ស៊ូ ផាត ឯ.ក | កំពង់ចាម |
| 25 | ក្រុមហ៊ុន យីង អ៊ីធើណល (ខេមបូឌា) | ស្វាយរៀង |
| 26 | ក្រុមហ៊ុន ហៃលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុន យីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 28 | ក្រុមហ៊ុន ខេមបូថៃ ហ្វូតវែ ខូអិលធីឌី | កំពត |
| 29 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 26 |
| 30 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់ អូតែល-កូបេ | ភ្នំពេញ |
| 31 | ក្រុមហ៊ុន ថាលាស | ភ្នំពេញ |
| 32 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 33 | ក្រុមហ៊ុន ឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 34 | ក្រុមហ៊ុន អេស៊ា អិចឆ្លជី ត្រាវែល | ភ្នំពេញ |
| 35 | ក្រុមហ៊ុន កូបេ យៃកេននីស វ៉េស្វូវ៉ែន | សៀមរាប |
| 36 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សេត និង ស្ប៉ា | សៀមរាប |
| 37 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 38 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 39 | សណ្ឋាគារ សុខាសៀមរាប | សៀមរាប |
| 40 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 41 | ក្រុមហ៊ុន ត្រេហ្ស៊ី អូអេស៊ីស | សៀមរាប |
| 42 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 43 | ក្រុមហ៊ុន អ៊ីបៅអេស៊ា | សៀមរាប |
| 44 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 45 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 46 | សណ្ឋាគារ ប៉ាវ៉ាឌីសអង្គរវីឡា | សៀមរាប |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 47 | សណ្ឋាគារ ឡូទុស ប្លង្គ រីសត | សៀមរាប |
| 48 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 49 | ក្រុមហ៊ុន វុត្ថៈ រីវើរ រីសត | សៀមរាប |
| 50 | ក្រុមហ៊ុន ឡាយ ហ្គូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |
| 51 | ក្រុមហ៊ុន ផ្កាចន្ទន៍ សៀមរាប យ៉ុងឆាង | សៀមរាប |
| 52 | សណ្ឋាគារ សិន្ធា មុន្នី | សៀមរាប |
| 53 | សណ្ឋាគារគូលែន | សៀមរាប |
| 54 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវែល សែរវីស | សៀមរាប |
| 55 | សណ្ឋាគារ ឋានសួគ៌សុខា | កំពត |